# ផាត់ពណ៌រូបត្រីស្រុកយើង

## Coloring fish in our country





Wonders of the Mekong

USAID
FROM THE AMERICAN PEOPLE

University of Nevada, Reno

# អារម្ភកថា

សៀវភៅ «**ផាត់ពណ៌រូបត្រីស្រុកយើង**» គឺជាស្នាដៃទី១ របស់គម្រោងអច្ឆរិយភាពនៃទន្លេមេគង្គ (Wonders of the Mekonkong) project។ សៀវភៅនេះ គឺ រៀបរៀងឡើង ក្នុងគោលបំណងណែនាំប្អូនៗឲ្យបានស្គាល់ពីភាពសម្បូរបែបនៃមច្ឆជាតិនៅក្នុងប្រទេសកម្ពុជា ពិសេស ត្រីក្នុងបឹងទន្លេសាប និងទន្លេមេគង្គ។ មិនតែប៉ុណ្ណោះ ក៏មានព័ត៌មានខ្លីៗ ពាក់ព័ន្ធនឹងវដ្តជីវិត ឈ្មោះជាភាសាខ្មែរ ឈ្មោះជាភាសាអង់គ្លេស ឈ្មោះវិទ្យាសាស្ត្រ ប្រវែងអតិបរមា លក្ខណៈសម្គាល់ និងជីវសាស្ត្ររបស់ត្រី ដែលមានរូបគំនូរក្នុងសៀវភៅនេះផងដែរ ប្រយោជន៍ដើម្បីបណ្ដុះគំនិតស្រឡាញ់ និងជួយថែរក្សាការពារមរតកធម្មជាតិដ៏មានតម្លៃនេះ។ ជាដំបូង ចូរប្អូនៗ ពិនិត្យមើលលើគំនូរពណ៌ធម្មជាតិរបស់ត្រីនៅទំព័រខាងឆ្វេង មុននឹងផាត់ពណ៌លើគំនូរ ស-ខ្មៅនៅទំព័រខាងស្ដាំ។

បន្ទាប់ពីផាត់ពណ៌រូបត្រីនេះរួចហើយ ចូរប្អូនៗសាកល្បងបង្កើតគំនិត និងស្នាដៃផ្ទាល់ខ្លួន ដោយគូររូបត្រីណាមួយដែលប្អូនស្គាល់ច្បាស់ ឬធ្លាប់បានឃើញក្នុងសៀវភៅណាមួយ ឬក៏ក្នុងទូរទស្សន៍។ បន្ទាប់មក ចូរប្អូនៗ សាកល្បងសរសេរព័ត៌មានអំពីត្រីនោះ តាមដែលប្អូនអាចដឹងបាន ឬក៏អាចសុំជំនួយពីនរណាម្នាក់។ ក្រុមការងាររបស់គម្រោង អច្ឆរិយភាពនៃទន្លេមេគង្គ សង្ឃឹមថា ប្អូនៗនឹងកាន់តែស្គាល់បានច្រើននូវឈ្មោះ និងរូបរាងរបស់មច្ឆជាតិដែលមានក្នុងប្រទេសយើង ព្រមទាំងចេះស្រឡាញ់ និងជួយថែរក្សា និងការពារផងដែរ។

ព័ត៌មានអំពីឈ្មោះជាភាសាខ្មែរ ឈ្មោះជាភាសាអង់គ្លេស ឈ្មោះវិទ្យាសាស្ត្រ ប្រវែងអតិបរមា លក្ខណៈសម្គាល់ និងជីវសាស្ត្ររបស់ត្រីនៅក្នុងសៀវភៅនេះ ត្រូវបានដកស្រង់ចេញពីគេហទំព័រ: http://ffish.asia/ គេហទំព័រ http://www.fishbase.org/ និងគេហទំព័រ http://www.iucnredlist.org/ ដោយលោក **ឈុត ឈាណា** អ្នកសម្របសម្រួលផ្នែកទំនាក់ទំនង និងអ្នករចនាទំព័រ របស់គម្រោងអច្ឆរិយភាពនៃទន្លេមេគង្គ។ ចំពោះរូបគំនូរពណ៌ធម្មជាតិ ត្រូវបានអនុញ្ញាតឲ្យយកមកប្រើប្រាស់ឡើងវិញដោយបណ្ឌិត **ហ្សេប ហូហ្គេន** អ្នកដឹកនាំគម្រោង អច្ឆរិយភាពនៃទន្លេមេគង្គ។ ចំពោះរូបគំនូរ ស-ខ្មៅ ត្រូវបានគូរយកលំនាំតាមរូបគំនូរពណ៌ធម្មជាតិទាំងស្រុង ដោយលោក **ឈុត ឈាណា**។

គម្រោងអច្ឆរិយភាពនៃទន្លេមេគង្គ

បណ្ឌិត **ហ្សេប ហូហ្គេន**

## *Bagarius yarrelli*

**IUCN:** Near Threatened



ត្រីក្របីធំ ឈ្មោះវិទ្យាសាស្ត្រ (*Bagarius yarrelli*) គឺជាប្រភេទត្រីទឹកសាប ត្រូវបានគេពិពណ៌នាថា មានដើមកំណើតពីទន្លេ មូថា មូឡា (Mutha Mula River) ក្នុងប្រទេសឥណ្ឌា។ ត្រីប្រភេទនេះ អាចមានប្រវែងដងខ្លួនអតិបរមាដល់ទៅ ២០០ ស.ម។ វារស់នៅតាមបាតទន្លេធំៗ ដែលមានទឹកថ្លា និងចរន្តទឹកហូរខ្លាំងតាមជ្រលងផ្ទាំងថ្មធំៗ។ ត្រីក្របីធំ ធ្វើចរាចរផ្លាស់ទីជាហ្វូង តាមពពួកសត្វផ្សេងៗ ដែលវាអាចចាប់ធ្វើជាចំណីបានដូចជា កំពឹស ត្រីតូចៗ និងពពួកសត្វល្អិតដែលរស់ក្នុងទឹក។ ប៉ុន្តែ មានមួយចំនួន បានធ្វើចរាចរផ្លាស់ទីទៅខ្សែទឹកខាងលើជាមួយត្រីគល់រាំង (*Catlocarpio siamensis*)

# ត្រីក្របីធំ

## ជាប្រភេទត្រីដែល
## កំពុងឈានទៅផុតពូជ



ផងដែរ។ ត្រីក្របីធំ ពង-កូនក្នុងទន្លេ ទីដែលវារស់នៅ។ វាត្រូវបានគេកត់ត្រាចូលក្នុងបញ្ជីក្រហម IUCN Red List (Near Threatend) ជាប្រភេទត្រីកំពុងឈានទៅផុតពូជក្នុងឆ្នាំ ២០០៩។ ការបំផ្លាញទីជម្រកពីសំណាក់មនុស្ស បម្រែបម្រួលអាកាសធាតុ និងការប្រកួតប្រជែងពីពពួកមច្ឆជាតិផ្សេងៗទៀត បានធ្វើឲ្យចំនួនត្រីក្របីធំក្នុងទន្លេ មានការធ្លាក់ចុះយ៉ាងខ្លាំង។




ត្រីគល់រាំង មានឈ្មោះវិទ្យាសាស្ត្រ (*Catlocarpio siamensis*) និងឈ្មោះជាភាសាអង់គ្លេស Giant barb គឺជាប្រភេទត្រីទឹកសាប មានស្រកាខ្លួនធំជាងគេក្នុងចំណោមត្រីមានស្រកាដទៃទៀត ដែលរស់នៅក្នុងទន្លេមេគង្គ។ ត្រីប្រភេទនេះ អាចមានប្រវែងដងខ្លួនអតិបរមា ដល់ទៅ៣០០ស.ម និងមានទម្ងន់៣០០គីឡូក្រាម។ វារស់នៅតាមដងទន្លេធំៗ ស្ទឹង បឹង និងតំបន់ទំនាបលិចទឹក ទីដែលវាអាចរកចំណីបានដូចជា សារាយ ផ្លុងតុង ផ្លែរុក្ខជាតិដែលដុះលូតលាស់មានផ្លែផ្កា នារដូវទឹកជំនន់ និងត្រីតូចៗ។ ត្រីគល់រាំងជំទង់ ភាគច្រើនវាអាចសម្របខ្លួនរស់នៅក្នុងស្រះ ត្រពាំង ស្ទឹង បឹង និងទំនាបលិចទឹក ខណៈត្រីគល់រាំងពេញវ័យ ហាក់ដូចចូលចិត្តធ្វើចរាចរចូលទៅរស់នៅក្នុងតំបន់អាងទឹកជ្រៅក្នុងទន្លេមេគង្គ។ នៅក្នុងប្រទេសកម្ពុជា ត្រីគល់រាំង



# ត្រីគល់រាំង

## ប្រភេទត្រីរងគ្រោះធ្ងន់ធ្ងរ

ពេញវ័យ បានធ្វើចរាចរផ្លាស់ទីចេញពីបឹងទន្លេសាប ចូលទៅរស់នៅក្នុងអាងទឹកជ្រៅៗ ក្នុងទន្លេមេគង្គ នាចុងរដូវប្រាំង។ ក្នុងឆ្នាំ ២០១១វាត្រូវបាន គេកត់ត្រាចូលក្នុងបញ្ជីក្រហម IUCN Red List (Critically Endangered) ជាប្រភេទត្រីរងគ្រោះជិតផុតពូជធ្ងន់ធ្ងរ។ ត្រីគល់រាំងត្រូវបានគេគិតថា ការអភិវឌ្ឍន៍ទំបន់វារិអគ្គិសនីនៅដងទន្លេមេ ក្នុងទន្លេមេគង្គ អាចនឹងធ្វើឲ្យមានការថយចុះចំនួនត្រីដែលនៅសេសសល់នេះបន្ថែមទៀត តាមរយៈ ការរំខានដល់ការធ្វើចរាចរផ្លាស់ទីរបស់ពួកវា។

***Channa micropeltes***

**Giant snakehead**

**IUCN:** Least Concern



ក្នុងវ័យជំទង់ហៅ ត្រីដៀប និងធំពេញវ័យហៅ ត្រីឆ្តោ មានឈ្មោះវិទ្យាសាស្ត្រ (*Channa micropeltes*) ឈ្មោះជាភាសាអង់គ្លេស Giant snakehead ។ វាជាប្រភេទត្រីទឹកសាប ដែលសាយភាយក្នុងតំបន់អាស៊ីអាគ្នេយ៍ ចាប់ពីទន្លេមេគង្គភាគខាងក្រោមក្នុងប្រទេសឡាវ «ព្រមទាំងដៃទន្លេផ្សេងៗ របស់វា ដូចជាទន្លេ សេបាំងហៀ» នៅអាងទន្លេចៅប្រាយ៉ា និងទន្លេមេក្លង ក្នុងប្រទេសថៃ នៅទន្លេសាប ក្នុងប្រទេសកម្ពុជា និងនៅតំបន់ដីសណ្តទន្លេមេគង្គ ក្នុងប្រទេសវៀតណាម ។ ត្រីដៀប/ឆ្តោ មានប្រវែងដងខ្លួនអតិបរមា ១៣០ ស.ម វាចាប់កំណើតឡើងនៅតាមទន្លេរាក់ៗ  វាលទំនាប តាមស្ទឹង ប្រឡាយ

# ត្រីដៀប (វ័យជំទង់)
# ត្រីឆ្តោ( ធំពេញវ័យ )

ជាប្រភេទត្រីដែល
មានការព្រួយបារម្ភតិចតួច



បឹងធំៗ ដែលមានទឹកនឹង ឬហូរយឺតៗ។ អាហារចម្បងរបស់ត្រីដៀប/ឆ្តោ គឺស៊ីវាត្រីផ្សេងៗ ប៉ុន្តែវាក៏ស៊ីពពួកចៃទឹក ឬសត្វល្អិតដែលរស់ក្នុងទឹកផងដែរ។ វាពង-កូននៅតាមស្ទឹង អូរ បឹងតូចៗ ដែលមានព្រៃលិចទឹក ឬរុក្ខជាតិដុះក្នុងទឹកក្រាស់ៗ។ ត្រីប្រភេទនេះ ត្រូវបានគេកត់ត្រាចូលក្នុងបញ្ជីក្រហម IUCN Red List (Least Concern) ជាប្រភេទត្រីដែលមានការព្រួយបារម្ភតិចតួចថានឹងរងគ្រោះផុតពូជ នៅក្នុងឆ្នាំ ២០១២។ ត្រីដៀប-ឆ្តោ ត្រូវបានគេចាត់ទុកថា ជាប្រភេទត្រីដែលពុំសូវទទួលរងផលប៉ះពាល់ពីមជ្ឈដ្ឋានទូទៅ ប៉ុន្តែ ហាក់ដូចជារងផលប៉ះពាល់ដោយតំបន់ ពីការបាត់បង់ទីជម្រក។




ត្រីក្រាយ មានឈ្មោះវិទ្យាសាស្ត្រ (*Chitala ornata*) និងឈ្មោះជាភាសាអង់គ្លេស Clown featherback ជាប្រភេទត្រីទឹកសាបដែលសាយភាយចាប់ពីទន្លេមេក្លង ក្នុងប្រទេសថៃភាគខាងកើត ទៅដល់អាងទន្លេមេគង្គ។ យើងអាចសម្គាល់ត្រីប្រភេទនេះបាន តាមរយៈចំណុចមូលខ្មៅ ៧ចំណុច ស្ថិតនៅក្បែរព្រុយពោះ តាមបណ្ដោយដងខ្លួនផ្នែកខាងកន្ទុយ។ ត្រីក្រាយ មានប្រវែងដងខ្លួនអតិបរមា ១០០ ស.ម និងទម្ងន់ ៥គីឡូក្រាម។ ត្រីប្រភេទនេះ ស្វែងរកចំណីនៅលើផ្ទៃទឹកក្នុងទន្លេធំ និងមធ្យម ដែលមានទឹកហូរ និងជាពិសេសក្នុងអាងទឹកជ្រៅៗតាមដងទន្លេមេគង្គ។ ត្រីក្រាយជាប្រភេទអជ្ឈប្បាតសត្វ វាស៊ីពពួកសត្វល្អិតដែលធ្វើសកម្មភាពនៅលើផ្ទៃទឹកនាពេលយប់ និងពពួកសត្វមានសម្បកដូចជាក្ដាម កំពឹសជាដើមជាអាហារ។ ត្រីក្រាយធ្វើចរាចរ

# ត្រីក្រាយ

## ជាប្រភេទត្រីដែល
## មានការព្រួយបារម្ភតិចតួច



ផ្លាស់ទីចូលទៅក្នុងតំបន់ព្រៃលិចទឹក ដូចជាបឹងទន្លេសាប ក្នុងអំឡុងពេលទឹកទន្លេមេគង្គចាប់ផ្តើមឡើង និងហូរឆ្លងកាត់ទន្លេសាប ចូលទៅបឹងទន្លេសាប ចាប់ពីខែមិថុនា ដល់ខែតុលា។ ត្រីក្រាយ ត្រូវបានគេកត់ត្រាចូលក្នុងបញ្ជីក្រហម IUCN Red List (Least Concern) ក្នុងឆ្នាំ ២០១២ ជាប្រភេទត្រីមានការព្រួយបារម្ភតិចតួច ដែលថានឹងអាចឈានទៅការផុតពូជ។ ការនេសាទហួសកម្រិតពីអតីតកាល និងទៅអនាគត ការបាត់បង់ និងការប្រែប្រួលទីជម្រកដោយសារការសាងសង់ទំបន់វារិអគ្គិសនី ទំនងជាបញ្ហាអវិជ្ជមាន ដែលបន្តប៉ះពាល់ដល់ជីវិតមច្ឆាប្រភេទនេះ។




ត្រីបបែលយក្ស មានឈ្មោះវិទ្យាសាស្ត្រ (*Himantura polylepis*) និងឈ្មោះជាភាសាអង់គ្លេស Giant freshwater whipray ជាត្រីបបែលទឹកសាបដ៏ធំបំផុតនៅក្នុងពិភពលោក។ វាមានទំហំខ្លួនអតិបរមាដល់ទៅ ២៤០ស.ម និងមានទម្ងន់ ៦០០គីឡូក្រាម។ វារស់នៅតាមដងទន្លេធំៗ ដែលមានស្រទាប់ភក់ ឬខ្សាច់នៅបាតទន្លេ ទីដែលវាអាចរកបាននូវប្រភេទសត្វអត់ឆ្អឹងខ្នង និងត្រីល្អិតៗជាចំណី ដូចជាទន្លេចៅប្រាយ៉ា និងទន្លេមេគង្គដែលតភ្ជាប់ទៅសមុទ្រនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ជាដើម។ ត្រីបបែលយក្ស ហាក់បង្ហាញវត្តមានគួរឲ្យកត់សម្គាល់នៅទន្លេមេគង្គលើ ក្នុងប្រទេសកម្ពុជា។ ចំណែកនៅ



# ត្រីបបែលយក្ស

ជាប្រភេទត្រី
ដែលជិតផុតពូជ

ក្នុងបឹងទន្លេសាប និងទន្លេមេគង្គ ក្នុងខេត្តកំពង់ចាម ខេត្តព្រៃវែង ចំនួនត្រីបបែលយកក្សមានការធ្លាក់ចុះប្រមាណ ៥០-៩០ភាគរយ ក្នុងរយៈពេល ២០-៣០ឆ្នាំចុងក្រោយនេះ។ វាត្រូវបានគេកត់ត្រាចូលក្នុងបញ្ជីក្រហម IUCN Red List (Endangered) ជាប្រភេទត្រីរងគ្រោះជិតផុតពូជក្នុងឆ្នាំ ២០១៦។ ការនេសាទហួសកម្រិតពីអតីតកាល និងទៅអនាគត ការបាត់បង់ និងការប្រែប្រួលទីជម្រកដោយសារការសាងសង់ទំបន់វារិអគ្គិសនី ទំនងជាបញ្ហាអរិជ្ជមានដែលបន្តប៉ះពាល់ដល់ជីវិតមច្ឆាដែលមានខ្លួនធំ និងអាយុវែងមួយប្រភេទនេះ។

## *Helicophagus leptorhynchus*

**IUCN:** Data Deficient



ត្រីប្រាកណ្តុរ មានឈ្មោះវិទ្យាសាស្ត្រ (*Helicophagus leptorhynchus*) ជាប្រភេទត្រីទឹកសាប ដែលមានរស់នៅពាសពេញទន្លេចៅប្រាយ៉ា និងក្នុងអាងទន្លេមេគង្គ ភាគកណ្តាល និងភាគខាងក្រោម នៃតំបន់អាស៊ីអាគ្នេយ៍ ក្នុងប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម។ ត្រីប្រាកណ្តុរ គឺជាប្រភេទត្រីដែលមិនធ្វើចរាចរផ្លាស់ទីចូលទៅក្នុងតំបន់ទំនាបលិចទឹកទេ។ ផ្ទុយទៅវិញ នៅពេលដែលកម្ពស់ទឹកចាប់ផ្តើមឡើងក្នុងរដូវទឹកជំនន់ ត្រីប្រភេទនេះ ក៏ធ្វើចរាចរផ្លាស់ទីឆ្ពោះទៅខ្សែទឹកខាងលើនៃតំបន់អាងទឹកជ្រៅ និងធ្វើចរាចរចុះមកខ្សែទឹកខាងក្រោមវិញ នាចុងរដូវទឹកជំនន់ ពោលគឺនៅពេលទឹកទន្លេ

# ត្រីប្រាកណ្ដុរ



រងថ្លា។ វាស៊ីពពួកគ្រុំ លៀស ខ្យង-ខ្ចៅជាអាហារ។ ដោយសារត្រីប្រាកណ្ដុរ ជាប្រភេទត្រីដែលធ្វើចរាចរក្នុងចម្ងាយជិត និងមធ្យម ដូច្នេះវាមិនសូវងាយរងគ្រោះដោយសារទំនប់វារិអគ្គិសនី ដូចប្រភេទត្រីដទៃទៀតឡើយ។ ក៏ប៉ុន្តែ គេគួរមានការសិក្សាស្រាវជ្រាវបន្ថែមទៀត ទៅលើរបបទឹកហូរប្រចាំឆ្នាំនៅក្នុងអាងទឹកជ្រៅ និងជម្រកសំខាន់ៗជាច្រើនទៀត ដែលវារស់នៅ។ ដោយខ្វះខាតទិន្នន័យ វាមិនត្រូវបានគេកត់ត្រាចូលក្នុងបញ្ជីក្រហម IUCN Red List ទេ។ ទោះយ៉ាងណា ត្រីប្រាកណ្ដុរ ត្រូវបានគេចាត់ទុកថា វាងាយរងគ្រោះដោយការបំពុលបរិស្ថាន។




ត្រីរៀលតុប មានឈ្មោះវិទ្យាសាស្រ្ត (*Gymnostomus siamensis*) និងឈ្មោះជាភាសាអង់គ្លេស Siamese mud carp ជាប្រភេទត្រីទឹកសាប ដែលរស់នៅច្រើនតាមដងទន្លេមេគង្គ និងអាងទន្លេមេក្លង និងទន្លេចៅប្រាយ៉ាក្នុងប្រទេសថៃផងដែរ។ ត្រីរៀលតុប មានប្រវែងដងខ្លួនអតិបរមា ២០ ស.ម វារស់នៅពាក់កណ្តាលកម្ពស់ទឹក ឬនៅបាតទន្លេតូច-ធំ ទីដែលវាអាចស្វែងរកចំណីបានដូចជា សារាយ ស្លែ ពពួកអតិសខុមប្រាណ និងប្លង់តុងរុក្ខជាតិ។ នៅក្នុងប្រទេសកម្ពុជា ខណៈពេលដែលកម្ពស់ទឹកចាប់ផ្តើមស្រកក្នុងខែតុលា ហ្វូងត្រីរៀលតុប ក៏ចាប់ផ្តើមធ្វើចរាចរផ្លាស់ទីជាប្រចាំឆ្នាំ ចេញពីតំបន់ព្រៃលិចទឹក។ ការធ្វើចរាចរនេះ ចេះតែកើនឡើងច្រើនជាលំដាប់ រហូតដល់ខែធ្នូ ជាពិសេសចេញពីបឹងទន្លេសាប ឆ្ពោះទៅក្នុងទន្លេមេគង្គ បន្ទាប់មក ក៏ធ្លាក់ចុះបន្តិចម្តងៗ។ ចាប់ពីខែតុលា ដល់ខែកុម្ភៈ ត្រីរៀលតុប ធ្វើចរាចរផ្លាស់ទីចេញពីស្រុកមុខកំពូល ខេត្តកណ្តាល មុនយប់ថ្ងៃពេញបូរមី ឆ្លងកាត់ទន្លេចតុមុខ ភ្នំពេញ ឆ្ពោះទៅល្បាក់ខោន។ នៅខ្សែទឹកខាងលើក្នុងខេត្តក្រចេះ វត្តមានត្រីរៀលតុបដ៏ច្រើនលើសលប់ នាយប់ថ្ងៃពេញបូរណ៍មី និងនៅសំបូរ

# ត្រីរៀលគុប

ជាប្រភេទត្រីដែល
មានការព្រួយបារម្ភតិចតួច



ខេត្តក្រចេះ នាថ្ងៃបន្ទាប់។ នៅក្បែរល្បាក់ខោន សកម្មភាពធ្វើចរាចរផ្លាស់ទីរបស់ត្រីរៀលគុប បន្តរហូតដល់ខែមិនា។ ក៏ប៉ុន្តែ ក្នុងខែមេសា វាធ្វើចរាចរ ចុះ-ឡើងទាំងពីរទិស។ ចាប់ពីខែឧសភា ដល់ កក្កដា នាដើមរដូវវស្សា ត្រីរៀលគុប ធ្វើចរាចរផ្លាស់ទីចុះមកខ្សែទឹកខាងក្រោមវិញ ចូលទៅតំបន់ ទំនាបព្រៃលិចទឹកក្នុងបឹងទន្លេសាប និងទៅតំបន់ដីសណ្តទន្លេមេគង្គ។ ត្រីរៀលគុប ត្រូវបានគេចាត់ទុកថាមានសារៈសំខាន់ណាស់សម្រាប់ប្រជាជន រស់នៅក្នុងតំបន់។ នៅក្នុងរដូវសម្បូរត្រីបំផុតចាប់ពីខែតុលា ដល់ខែកុម្ភៈ ជារៀងរាល់ឆ្នាំនៅតាមដងទន្លេសាប ប្រជាជនកម្ពុជានិយមយកត្រីរៀលគុប ធ្វើជាត្រីប្រហុក និងត្រីឆ្អើរ ទុកសម្រាប់រដូវខ្សត់ត្រី ។ ត្រីរៀលគុប ត្រូវបានគេកត់ត្រាចូលក្នុងបញ្ជីក្រហម IUCN Red List (Least Concern) ក្នុងឆ្នាំ ២០១២ ជាប្រភេទត្រីមានការព្រួយបារម្ភតិចតួច ដែលនឹងអាចឈានទៅដល់ការផុតពូជ។ ទោះជាយ៉ាងណា សំណង់ទំបន់វារិអគ្គិសនីនៅតាមដង ទន្លេមេគង្គ អាចនឹងជាផលអវិជ្ជមាន សម្រាប់ត្រីប្រភេទនេះ។




ត្រីឆ្កោក មានឈ្មោះវិទ្យាសាស្ត្រ (*Cyclocheilichthys enoplos*) ជាប្រភេទត្រីទឹកសាប រស់នៅក្នុងដៃទន្លេធំៗ របស់ទន្លេមេគង្គក្រោមទាំងអស់។ វាមានប្រវែងដងខ្លួនអតិបរមា ៧៥ ស.ម ខណៈប្រវែងដងខ្លួនជាទូទៅ ៤៥ ស.ម។ ត្រីឆ្កោក រស់នៅពាក់កណ្តាលកម្ពស់ទឹកទន្លេ រហូតដល់បាតទន្លេ ទីដែលវាអាចរកចំណីចម្បងដូចជា ឫសរុក្ខជាតិ ប្លង់តុងសត្វ និងស្លែបៃតង។ ប៉ុន្តែ កូនតូចៗរបស់វា ក៏ស៊ីប្លង់តុងសត្វដែរ ខណៈត្រីឆ្កោកពេញវ័យចាប់កូនតូចៗរបស់សត្វល្អិតទើបនឹងញាស់ និងពពួកសត្វមានសម្បកដូចជា ខ្យង ខ្ចៅ ក្តាម កំពិស បង្កង និងត្រី ជាអាហារ។ ត្រីប្រភេទនេះ ពង-កូន អំឡុងរដូវភ្លៀងធ្លាក់ នៅក្នុងតំបន់ព្រៃលិចទឹក និងវិលត្រឡប់ចូលទៅក្នុងទន្លេវិញ ចាប់ពីខែតុលា ដល់ខែធ្នូ។ នៅក្នុងទន្លេមេគង្គ ត្រីឆ្កោក ធ្វើចរាចរផ្លាស់ទីចេញពីបឹងទន្លេសាប ឆ្លងកាត់ភ្នំពេញ ឆ្ពោះទៅល្បាក់ខោនខ្សែទឹកខាងលើ ចាប់ពីខែ វិច្ឆកា ដល់ខែកុម្ភៈ។ ត្រីប្រភេទនេះ នឹងធ្វើចរាចរផ្លាស់ទីត្រឡប់មកខ្សែ

# ត្រីឆ្កោក

ជាប្រភេទត្រីដែល
មានការព្រួយបារម្ភតិចតួច



ទឹកខាងក្រោមចូលទៅក្នុងបឹងទន្លេសាបវិញ ក្នុងខែឧសភា ដល់ខែសីហា និងមួយចំនួនទៀត បន្តដំណើរទៅតំបន់ដីសណ្តទន្លេមេគង្គ ក្នុងប្រទេសវៀតណាមជាទីដែលពួកវាបន្តរស់នៅរហូតដល់ខែតុលា-វិច្ឆិកា។ ត្រីឆ្កោក ត្រូវបានគេកត់ត្រាចូលក្នុងបញ្ជីក្រហម IUCN Red List (Least Concern) ក្នុងឆ្នាំ ២០១១ ជាប្រភេទត្រីដែលមានការព្រួយបារម្ភតិចតួចថានឹងឈានទៅដល់ជាប្រភេទត្រីរងគ្រោះផុតពូជ។ ការនេសាទហួសកម្រិតពីអតីតកាល និងទៅអនាគត ការបំពុលបរិស្ថាន ការបាត់បង់ និងការប្រែប្រួលទីជម្រកដោយសារការសាងសង់ទំបន់វារិអគ្គិសនី ដែលជាផលរំខានដល់ការធ្វើចរាចរផ្លាស់ទី សុទ្ធតែជាចំណុចអវិជ្ជមាន ដែលនឹងប៉ះពាល់ដល់ជីវិតមច្ឆាប្រភេទនេះ។




ត្រីប្រម៉ា មានឈ្មោះវិទ្យាសាស្ត្រ (*Boesemania microlepis*) និងឈ្មោះជាភាសាអង់គ្លេស Boeseman croaker មានប្រវែងដងខ្លួនអតិបរមា ១០០ ស.ម និងមានទម្ងន់អតិបរមា ១៨ គ.ក។ វារស់នៅក្នុងទន្លេធំៗ ដែលមានទឹកហូរ នៅបឹងទន្លេសាប និងនៅតាមអន្លង់ជ្រៅៗក្នុងទន្លេមេគង្គ ពិសេសនៅខេត្តក្រចេះ និងស្ទឹងត្រែង។ ទាំងខួបប្រាំងខួបវស្សា។ ត្រីប្រម៉ា វាស៊ីចៃទឹក សត្វល្អិតដែលរស់ក្នុងទឹក និងត្រីល្អិតៗជាអាហារ។ ត្រីប្រភេទនេះ ហាក់ដូចជាមិនសូវមានទម្លាប់ធ្វើចរាចរផ្លាស់ទីច្បាស់លាស់ទេ។ ការកកើតឡើងយ៉ាងគំហុកនូវចំនួនត្រីប្រម៉ានៅក្នុងតំបន់ទឹកជ្រៅ នៃទន្លេមេគង្គ ដូច្នេះ វាត្រូវបាន

# ត្រីកាបស

ជាប្រភេទត្រីដែល
កំពុងរងការគំរាមកំហែង



គេសន្និដ្ឋានថា វាអាចដាក់ន្លែងពង-កូនរបស់វាតែម្តង។ ត្រីប្រម៉ា ត្រូវបានគេកត់ត្រាចូលក្នុងបញ្ជីក្រហម IUCN Red List (Near Threatened) ក្នុងឆ្នាំ ២០១១ ជាប្រភេទត្រីដែលកំពុងរងការគំរាមកំហែង និងឈានទៅជិតផុតពូជ។ ការនេសាទហួសកម្រិតពីអតីតកាល និងទៅអនាគត ការបាត់បង់ និងការប្រែប្រួលទីជម្រកដោយសារការសាងសង់ទំបន់វារិអគ្គិសនី ទំនងជាបញ្ហាអវិជ្ជមាន ដែលបន្តប៉ះពាល់ដល់ជីវិតមច្ឆាប្រភេទនេះ។

## *Pangasius krempfi*

**IUCN:** Vulnerable



ត្រីបង់ឡាវ មានឈ្មោះវិទ្យាសាស្ត្រ (*Pangasius krempfi*) ជាប្រភេទត្រីរស់នៅក្នុងទឹកសាបផង ទឹកប្រៃផង ពោលគឺវារកចំណីនៅតំបន់ឆ្នេរសមុទ្រ និងធ្វើចរាចរផ្លាស់ទីចូលទៅបណ្ដាញទឹកសាបសំខាន់ៗ ដូចជាទន្លេមេគង្គជាដើម ដើម្បីពង-កូន។ ប៉ុន្តែ គេមិនដឹងថា វាពង-កូននៅទីណាជាក់លាក់ទេ តែត្រូវបានគេសន្មតថា វាពង-កូននៅក្នុងទន្លេមេគង្គផ្នែកខាងលើ។ ត្រីបុងឡាវ មានប្រវែងដងខ្លួនអតិបរមា ១២០ ស.ម និងទម្ងន់ ១៤គ.ក។ វាស្ថិតក្នុងអម្បូរត្រីប្រា pangasiid តែមួយគត់ ដែលចំណាយពេលភាគច្រើននៃជីវិតរស់នៅក្នុងទឹកប្រៃ គឺនៅក្នុងសមុទ្រ ប៉ុន្តែ វាធ្វើចរាចរផ្លាស់ទីទៅពង-កូន នៅក្នុងទឹកសាប និងទន្លេមេគង្គ។ ត្រីប្រភេទនេះ ត្រូវបានគេសន្មតថា យ៉ាងហោចណាស់ ក៏មានពីរដំណាក់កាលនៃការធ្វើចរាចរផ្លាស់ទីដែរ។ ទីមួយ គឺការធ្វើចរាចរផ្លាស់ទីចាប់ពីខែ ឧសភា ដល់ កញ្ញា ដោយចេញពីភាគខាងត្បូងនៃល្បាក់ខោន ឆ្ពោះទៅខ្សែទឹកខាងលើ តាមបណ្ដោយដងទន្លេមេគង្គ

# ត្រីបុងឡាវ
## ជាប្រភេទត្រីដែល ងាយរងគ្រោះ



ឈាងខុង ជិតព្រំដែន ឡាវ-ថៃ-មីយ៉ាន់ម៉ា ដើម្បីពង-កូន។ ទីពីរ គឺការធ្វើចរាចរផ្លាស់ទីចុះទៅខ្សែទឹកខាងក្រោម ចាប់ពីខេត្តស្ទឹងត្រែង រហូតដល់ខេត្តកំពង់ចាម ក្នុងរដូវពង-កូនក្នុងចន្លោះខែ ឧសភា ដល់ខែសីហា តែមិនត្រូវបានគេដឹងថា វាពង-កូននៅកន្លែងណាទេ។ ត្រីបុងឡាវ ត្រូវបានគេកត់ត្រាចូលក្នុងបញ្ជីក្រហម IUCN Red List (Vulnerable) ក្នុងឆ្នាំ ២០១១ ជាប្រភេទត្រីងាយរងគ្រោះ ដែលនឹងឈានទៅរកការផុតពូជ។ កត្តាគំរាមកំហែងដ៏សំខាន់នាពេលបច្ចុប្បន្នចំពោះត្រីប្រភេទនេះគឺ ការនេសាទហួសកម្រិតក្នុងពេលនៃការធ្វើចរាចរផ្លាស់ទីរបស់វាក្នុងសមុទ្រ។ ក្រៅពីនេះ ត្រីបុងឡាវងាយប្រឈមនឹងទំបន់វារិអគ្គិសនីនៅតាមបណ្តោយទន្លេមេគង្គ ដែលជាផ្លូវធ្វើចរាចរផ្លាស់ទីដើម្បីពង-កូនរបស់វាណាស់។

***Pangasius macronema***

**IUCN:** Near Threatened



ត្រីឈ្វៀតឆ្នូត មានឈ្មោះវិទ្យាសាស្ត្រ (*Pangasius macronema*) ជាប្រភេទត្រីទឹកសាប ដែលរស់នៅជាហ្វូងធំៗ នៅតាមទន្លេ បឹង និងអាងស្តុកទឹក ដែលមានចរន្តទឹកហូរខ្លាំង។ ត្រីឈ្វៀតឆ្នូត មានប្រវែងដងខ្លួនអតិបរមា ៣០ស.ម។ វាស៊ីពពួកសិប្បីជាតិ ដង្កូវទឹក សត្វល្អិត ត្រីល្អិតៗ និងកំពឹសជាអាហារ។ ត្រីប្រភេទនេះ វាធ្វើចរាចរផ្លាស់ទីចូលទៅក្នុងដៃទន្លេ និងព្រៃលិចទឹកជាមួយត្រីឈ្វៀតក្តារ (*Pseudolais pleurotaenia*) នឹងពពួកត្រីមានស្រកា cyprinid ជាច្រើនប្រភេទទៀត នៅពេលទឹកចាប់ផ្តើមល្អក់។ ជាប្រភេទត្រីធ្វើចរាចរផ្លាស់ទី ត្រីឈ្វៀតឆ្នូត ពឹងផ្អែកលើទីកន្លែងណាដែលមាន

# ត្រីឈ្វៀតឆ្នូត

ជាប្រភេទត្រីដែល
មានការព្រួយបារម្ភតិចតួច



ទឹកជ្រៅៗ ដើម្បីការពារខ្លួនក្នុងពេលធ្វើចរាចរផ្លាស់ទីឆ្ពោះទៅខ្សែទឹកខាងលើ នៃទន្លេមេគង្គ។ ជាទូទៅ ត្រីឈ្វៀតឆ្នូត ធ្វើចរាចរផ្លាស់ទីនាពេលយប់ ខណៈពេលថ្ងៃ ពួកវាឈប់សម្រាកប្រមូលផ្តុំគ្នានៅកន្លែងទឹកជ្រៅៗ។ ត្រីប្រភេទនេះ ត្រូវបានគេកត់ត្រាចូលក្នុងបញ្ជីក្រហម IUCN Red List (Least Concern) ក្នុងឆ្នាំ ២០០៩ ជាប្រភេទត្រីដែលមានការព្រួយបារម្ភតិចតួច ថានឹងឈានទៅដល់ការផុតពូជ។ កត្តាគំរាមកំហែងនាពេលបច្ចុប្បន្នចំពោះត្រីប្រភេទនេះ គឺមិនត្រូវបានគេដឹងនៅឡើយទេ។




ត្រីកែ មានឈ្មោះវិទ្យាសាស្ត្រ (*Pangasius conchophilus*) ជាប្រភេទត្រីទឹកសាប ដែលរស់នៅក្នុងទន្លេចៅប្រាយ៉ា ទន្លេបាងបាគង្គ ក្នុងប្រទេសថៃ ទន្លេមេគង្គ និងទន្លេសាបក្នុងប្រទេសកម្ពុជាផងដែរ។ ត្រីកែ មានប្រវែងដងខ្លួនអតិបរមា ១២០ ស.ម។ ត្រីប្រភេទនេះ វារស់នៅក្នុងទន្លេធំៗ ដែលមានចរន្តទឹកហូរលឿនត្របាញ់ និងទន្លេទឹកជ្រៅដែលមានចរន្តទឹកហូរយឺត ព្រមទាំងមានចូលទៅក្នុងតំបន់ព្រៃលិចទឹកផងដែរ។ កូនត្រីកែតូចៗ ស៊ីកំពឹស និងពពួកសត្វល្អិត ខណៈត្រីកែជំទង់ និងពេញវ័យ ពួកវាស៊ីកំពឹស និងពពួកសត្វល្អិត ជាពិសេសសិប្បីជាតិ ដែលបានបំពេញក្រពះរបស់វាដ៏ច្រើនលើសលប់ជាងប្រភេទត្រីផ្សេងក្នុងអម្បូរដូចគ្នានេះ។ នៅរដូវវស្សា ជាពេលវេលាដែលត្រីកែត្រូវចាកចេញពីទន្លេមេគង្គ ចូលទៅក្នុងតំបន់ព្រៃលិចទឹក ព្រមទាំងស៊ីផ្លែរុក្ខជាតិនៅទីនោះ ភាគច្រើនជាងចំណីផ្សេងៗ ឯទៀត។ ក្នុងរដូវប្រាំង ត្រីកែចូលទៅជ្រកកោនក្នុងអាងទឹកជ្រៅ និងទន្លេធំៗ។ ត្រីប្រភេទ

# ត្រីកែ

ជាប្រភេទត្រីដែល
មានការព្រួយបារម្ភតិចតួច



នេះ វាពង-កូននៅតាមដងទន្លេធំៗ ក្នុងរដូវទឹកជំនន់ ហើយកូនតូចៗរបស់វា ចូលទៅក្នុងតំបន់លិចទឹក។ ត្រីកែធ្វើចរាចរផ្លាស់ទីឆ្ពោះទៅខ្សែទឹកខាងលើទន្លេមេគង្គជាហ្វូង ចាប់ពីខែឧសភា ដល់ខែកក្កដា និងត្រូវបានគេគិតថា វាមិនមែនជាប្រភេទត្រីធ្វើចរាចរផ្លាស់ទីក្នុងចម្ងាយផ្លូវឆ្ងាយទេ។ ត្រីកែ ត្រូវបានគេកត់ត្រាចូលក្នុងបញ្ជីក្រហម IUCN Red List (Least Concern) ក្នុងឆ្នាំ ២០១២ ជាប្រភេទត្រីដែលមានការព្រួយប្រារម្ភតិចតួច ដែលអាចឈានដល់ប្រភេទត្រីរងគ្រោះផុតពូជ។ ប៉ុន្តែ ការនេសាទហួសកម្រិតពីអតីតកាល និងទៅអនាគត ការបាត់បង់ និងការប្រែប្រួលទីជម្រក ដោយសារការសាងសង់ទំបន់វារិអគ្គិសនី ទំនងជាបញ្ហាអវិជ្ជមាន ដែលបន្តប៉ះពាល់ដល់ជីវិតមច្ឆាប្រភេទនេះ។ មិនតែប៉ុណ្ណោះ ត្រីប្រភេទនេះ បានរងផលប៉ះពាល់ពីការបាត់បង់ព្រៃលិចទឹកជាជម្រកក្នុងបឹងទន្លេសាប និងតាមដងទន្លេមេគង្គទាំងមូល។




ត្រីពោព្រុយ មានឈ្មោះវិទ្យាសាស្ត្រ (*Pangasius sanitwongsei*) និងឈ្មោះជាភាសាអង់គ្លេស Giant pangasius ជាប្រភេទត្រីទឹកសាប រស់នៅក្នុងទន្លេធំៗ និងដៃទន្លេ ដែលមានព្រៃលិចទឹកព័ទ្ធជុំវិញ ដូចជាអាងទន្លេចៅប្រាយ៉ា អាងទន្លេមេគង្គ ដោយវាប្រើប្រាស់អាងទឹកជ្រៅសម្រាប់ជ្រកកោនក្នុងរដូវប្រាំង។ ត្រីពោព្រុយ មានប្រវែងដងខ្លួនអតិបរមា ៣០០ស.ម និងទម្ងន់អតិបរមា ៣០០គ.ក។ វាស៊ីពពួកក្តាម កំពឹល បង្កង ព្រមទាំងសាកសពសត្វផ្សេងៗ ដែលអណ្តែតទឹក។ វាជាប្រភេទត្រីធ្វើចរាចរផ្លាស់ទី ពង-កូនមុនរដូវភ្លៀង ដោយកូនតូចៗរបស់វាអាចលូតលាស់ដល់ប្រវែងប្រហែល ១០ស.ម នៅពាក់កណ្តាលខែមិថុនា។ ត្រីពោព្រុយ ត្រូវបានគេកត់ត្រាចូលក្នុងបញ្ជីក្រហម IUCN Red List (Critically Endangered) ក្នុងឆ្នាំ ២០០៩ ជាប្រភេទ

# ត្រីពោព្រុយ

## ជាប្រភេទត្រីដែលរងគ្រោះធ្ងន់ធ្ងរ



ត្រីរងគ្រោះធ្ងន់ធ្ងរជិតផុតពូជ។ កត្តាគំរាមកំហែងដ៏សំខាន់នាពេលបច្ចុប្បន្នចំពោះត្រីប្រភេទនេះគឺ ការនេសាទហួសកម្រិត ការបាត់បង់ទីជម្រក និងការបំពុលបរិស្ថាន។ ក្រៅពីនេះ ត្រីពោព្រុយ ទំនងជាបានរងផលប៉ះពាល់ដោយការបំផ្លិចបំផ្លាញតំបន់មានទឹកហូរលឿន និងថ្មប៉ប្រះទឹក ដែលជាផ្នែកមួយនៃគម្រោងកែលម្អនាវាចរណ៍ និងការសាងសង់ទំបន់វារិអគ្គិសនីនៅតាមដងទន្លេមេគង្គជាដើម។ គម្រោងទាំងនេះ បានជះឥទ្ធិពលលើវដ្តធម្មជាតិនៃទឹកជំនន់/គ្រោះរាំងស្ងួត នៅតាមដងទន្លេទាំងមូល ព្រមទាំងឥរិយាបថនៃការធ្វើចរាចរផ្លាស់ទីរបស់ត្រីពោព្រុយផងដែរ។




ត្រីក្រពតខ្មែរ មានឈ្មោះវិទ្យាសាស្ត្រ (*Pao cambodgiensis*) ជាប្រភេទត្រីទឹកសាប ដែលមានរស់នៅពាសពេញក្នុងតំបន់អាស៊ីអាគ្នេយ៍ ដូចជានៅក្នុងអាងទន្លេមេគង្គក្រោម ព្រមទាំងដៃទន្លេសំខាន់ៗផងដែរ ដូចជាទន្លេសេកុងជាដើម។ ត្រីក្រពតខ្មែរ មានប្រវែងដងខ្លួនអតិបរមា ១៥.៣ ស.ម។ ត្រីប្រភេទនេះ វាច្រើបស៊ីសិប្បីជាតិ និងប្លង់តុងសត្វជាអាហារ ជួនកាលក៏អាចច្រើបមនុស្សផងដែរ បើវាបានជួបជាអាហារ។ ចំពោះការបន្តពូជ ត្រីក្រពត

# ត្រីក្រពតខ្មែរ

ជាប្រភេទត្រីដែល
មានការព្រួយបារម្ភតិចតួច



ខ្មែរ មិនត្រូវបានគេដឹងថាវា ពង-កូន ក្នុងពេលណា នៅទីណាឡើយ។ ដោយខ្វះខាតទិន្នន័យ ត្រីប្រភេទនេះ វាមិនត្រូវបានគេកត់ត្រាចូលក្នុងបញ្ជីក្រហម IUCN  IUCN Red List ទេ។ កត្តាគំរាមកំហែងនាពេលបច្ចុប្បន្នចំពោះត្រីក្រពតខ្មែរ មិនត្រូវបានគេដឹងឡើយ។




ត្រីត្រសក់ (*Probarbus jullieni*) មានឈ្មោះជាភាសាអង់គ្លេស Isok barb គឺជាប្រភេទត្រីទឹកសាប រស់នៅក្នុងទន្លេមេគង្គ ដែលមានស្រកាធំៗ ព្រមទាំងឆ្នូតខ្មៅ៦ តាមបណ្តោយដងខ្លួនចាប់ពីស្រកីដល់កន្ទុយ។ ត្រីប្រភេទនេះ អាចមានប្រវែងដងខ្លួនអតិបរមាដល់ទៅ១៥០ស.ម និងមានទម្ងន់ ៧០គីឡូក្រាម។ ត្រីត្រសក់ រស់នៅតាមដងទន្លេធំៗ ដែលមានស្រទាប់ខ្សាច់ ឬគ្រួស និងមានសិប្បិជាតិរស់នៅ ព្រមទាំងមានរុក្ខជាតិទឹកផងដែរ ជាកន្លែងដែលវាអាចរកចំណីបាន។ ត្រីត្រសក់ ធ្វើចរាចរផ្លាស់ទីចេញពីខេត្តកំពង់ចាម ក្នុងប្រទេសកម្ពុជា ចាប់ពីខែតុលា ដល់ ខែកុម្ភៈ ឆ្លងកាត់ល្បាក់ខោន ឆ្ពោះទៅគោលដៅនៃខេត្តឆៀងខុង ផ្នែកខាងលើទន្លេមេគង្គក្នុងប្រទេសថៃ។ មានព័ត៌មានខ្លះពីអ្នកនេសាទ បានឲ្យដឹងថា ត្រីត្រសក់បាន

# ត្រីត្រសក់

## ជាប្រភេទត្រីដែល
## កំពុងឈានទៅផុតពូជ



ធ្វើចរាចរផ្លាស់ទីបន្តទៅទៀត ឆ្ពោះទៅដៃទន្លេ «ណាមតា» ក្នុងប្រទេសឡាវ ដើម្បីពង-កូន ក្នុងខែមិនា-មេសា។ ត្រីត្រសក់ ត្រូវបានគេកត់ត្រាចូលក្នុងបញ្ជីក្រហម IUCN Red List (Endangered) ជាប្រភេទត្រីរងគ្រោះជិតផុតពូជក្នុងឆ្នាំ ២០១១។ បច្ចុប្បន្ន ត្រីត្រសក់កំពុងប្រឈមនឹងការនេសាទហួសកម្រិត ការបំផ្លិចបំផ្លាញទីជម្រក និងការកសាងទំនប់វារិអគ្គិសនីធំៗ ព្រមទាំងជាគោលដៅរបស់អ្នកនេសាទ ជាប្រភេទត្រីដែលត្រូវនេសាទយកពងផងដែរ ក្នុងរដូវត្រីពង។




ត្រីកញ្ចុះថ្ម មានឈ្មោះវិទ្យាសាស្ត្រ (*Pseudomystus siamensis*) និងឈ្មោះជាភាសាអង់គ្លេស Asian bumblebee catfish ជាប្រភេទត្រីទឹកសាប ដែលមានរស់នៅពាសពេញក្នុងតំបន់អាស៊ីអាគ្នេយ៍ ដូចជានៅក្នុងអាងទន្លេមេគង្គក្រោម ទន្លេមេក្លុង ទន្លេចៅប្រាយ៉ា ប្រព័ន្ធទន្លេនៅសងខាងជម្រាលនៃឧបទ្វីបម៉ាឡេ និងនៅតាមបណ្ដោយឆ្នេរសមុទ្រនាភាគអាគ្នេយ៍ក្នុងប្រទេសថៃ ជាដើម។ វាក៏មានរស់នៅច្រើន នៅតាមបណ្ដោយដងទន្លេមេគង្គក្រោម និងនៅក្នុងដៃទន្លេសំខាន់ៗ ដូចជាទន្លេសេកុងជាដើម។ ត្រីកញ្ចុះថ្ម មានប្រវែងដងខ្លួនអតិបរមា ១៥ស.ម។ វាស៊ីកូនតូចៗ របស់វារិសត្វ ព្រមទាំង

## ត្រីកញ្ចុះថ្ម

ជាប្រភេទត្រីដែល
មានការព្រួយបារម្ភតិចតួច



កន្ទុំរុយផងដែរជាអាហារ។ ត្រីកញ្ចុះថ្ម ពង-កូន អំឡុងពេលរដូវវស្សាចាប់ផ្តើមចូលមកដល់ ដោយយើងអាចឃើញកូនតូចៗរបស់វាជាប់មងរបស់អ្នកនេសាទ នៅក្នុងខែឧសភា។ ត្រីកញ្ចុះថ្ម ត្រូវបានគេកត់ត្រាចូលក្នុងបញ្ជីក្រហម IUCN Red List (Least Concern) ក្នុងឆ្នាំ ២០០៩ ជាប្រភេទត្រីដែលមានការព្រួយបារម្ភតិចតួច ថានឹងឈានដល់ទៅដល់ប្រភេទរងគ្រោះដាច់ពូជ។ កត្តាគំរាមកំហែងនាពេលបច្ចុប្បន្នចំពោះត្រីប្រភេទនេះមិនត្រូវបានគេដឹងឡើយ។



***Pseudomystus siamensis***

**IUCN:** Vulnerable

ត្រីក្បក មានឈ្មោះវិទ្យាសាស្ត្រ (*Tenualosa thibaudeaui*) និងឈ្មោះជាភាសាអង់គ្លេស Laotian shad ជាប្រភេទត្រីដែលគេសន្មតថា បានធ្វើចរាចរជាង ២០០០ គីឡូម៉ែត្រពីសមុទ្រ ចូលមករស់នៅតាមដងទន្លេមេ តំបន់ទំនាបតាមដៃទន្លេ និងតំបន់ទំនាបលិចទឹក ក្នុងទន្លេមេគង្គ។ ត្រីក្បក មានប្រវែងដងខ្លួនអតិបរមា ៣០ ស.ម និងមានទម្ងន់ ១គីឡូក្រាម ជាប្រភេទត្រីស៊ីតែចំណីតូចល្អិតៗ ដែលយើងមិនអាចមើលឃើញដោយភ្នែកទទេបាន ដូចជាផ្លូងតុងរុក្ខជាតិ ផ្លូងតុងសត្វ និងបាក់តេរី និងរូបធាតុតូចល្អិតផ្សេងៗដែលមានក្នុងទឹក។ ត្រីក្បក ធ្វើចរាចរផ្លាស់ទីចេញពីខ្សែទឹកខាងលើ ក្នុងប្រទេសឡាវ ចុះមកក្នុងប្រទេសកម្ពុជា ក្នុងខែកក្កដា ដោយអាចហូរតាមចរន្តទឹកជំនន់ពីទន្លេមេគង្គ និងចូលទៅក្នុងបឹងទន្លេសាប។ ក្នុងពេលទឹកបឹងទន្លេសាបស្រកចុះ ត្រីក្បក ក៏ធ្វើចរាចរផ្លាស់ទីចេញពីបឹងទន្លេសាបចូលទៅក្នុងទន្លេមេគង្គវិញ។ ខណៈពេលទឹកទន្លេមេគង្គស្រកចុះ វាក៏ចាប់ផ្តើម

# ត្រីក្បក

ជាប្រភេទត្រីដែល
ងាយរងគ្រោះ



ធ្វើដំណើរឆ្លងកាត់ល្បាក់ខោន ឆ្ពោះទៅភាគខាងត្បូងប្រទេសឡាវវិញ។ យ៉ាងហោចណាស់ មានតំបន់ពីរដែលត្រីប្រភេទនេះ រស់ច្រើនក្នុងអាងទន្លេមេគង្គ។ ទីមួយ នៅជុំវិញតំបន់សាយ៉ាបូរី ភាគខាងជើងប្រទេសឡាវ និងផ្នែកខ្សែទឹកខាងលើ។ ទីពីរ នៅទន្លេមេគង្គក្រោម ដែលវាធ្វើដំណើរចេញតំបន់ដីសណ្តទន្លេមេគង្គក្នុងប្រទេសវៀតណាម ចូលទៅតំបន់ប៉ាកសាន ភាគខាងក្រោមទីក្រុងវៀងច័ន្ទ ប្រទេសឡាវ។ ត្រីក្បក ត្រូវបានគេគិតថាពងកូននៅភាគកណ្តាលនៃទន្លេមេគង្គ ដោយត្រីជំទង់ៗ រកចំណីនៅទីជម្រកក្នុងតំបន់ទំនាបលិចទឹក និងដៃទន្លេ។ ត្រីក្បក ត្រូវបានគេកត់ត្រាចូលក្នុងបញ្ជីក្រហម IUCNRed List (Vulnerable) ជាប្រភេទត្រីងាយរងគ្រោះផុតពូជ ក្នុងឆ្នាំ ២០១១។ តំបន់អាងទឹកជ្រៅនៅតាមដងទន្លេមេគង្គ រវាងខេត្តស្ទឹងត្រែង និងខេត្តក្រចេះ បើមានការសាងសង់ទំនប់វារិអគ្គិសនី នោះដង់ស៊ីតេមច្ឆជាតិប្រភេទនេះ នឹងងាយទទួលរងផលប៉ះពាល់ខ្លាំងបំផុត។

## *Wallago attu*

**IUCN:** Near Threatened



ត្រីសណ្តាយ មានឈ្មោះវិទ្យាសាស្ត្រ (*Wallago attu*) និងឈ្មោះជាភាសាអង់គ្លេស Wallago ជាប្រភេទត្រីទឹកសាប រស់នៅក្នុងទន្លេ អូរ ស្ទឹង បឹងបួរ អាងស្តុកទឹក និងតំបន់វាលទំនាបលិចទឹក។ ត្រីសណ្តាយមានប្រវែងដងខ្លួនអតិបរមា ២៤០ ស.ម។ វាជាប្រភេទត្រី ល្មោភស៊ីមិនចេះឆ្អែតដ៏ធំមួយដែលស៊ីសាច់ជាអាហារ និងធំលូតលាស់នៅតាមមាត់ច្រាំងទន្លេ អូរដែលមានដុះស្មៅ និងភាគច្រើនវាលាក់ខ្លួននៅក្នុងរន្ធ។ ត្រីសណ្តាយ ជាប្រភេទត្រីដែលមានសកម្មភាពយឺត ស្ងប់ស្ងាត់ ស្វែងរកចំណីនៅបាតទន្លេជ្រៅៗ មានទឹកនឹង ឬទឹកហូរតិចៗ ព្រមទាំងនៅស្រទាប់បាតក្រោមដែលមានភក់ ឬល្បាប់។ ត្រីសណ្តាយវ័យជំទង់ អាហារចម្បងរបស់វាគឺសត្វល្អិត ចំណែកឯត្រីពេញវ័យ ស៊ីត្រីតូចៗ កំពឹល ក្តាម និងសិប្បីជាតិ។ វាធ្វើចរាចរផ្លាស់ទីចូលទៅក្នុងស្ទឹងតូចៗ ប្រឡាយ និងតំបន់លិចទឹក ក្នុងរដូវទឹកជំនន់ដើម្បីពង-កូន។ ជាទូទៅ ត្រីប្រភេទនេះពងដាក់ជាប់នឹងរុក្ខជាតិដែលដុះក្នុងទឹក ឬស្មៅ ហើយ

# ត្រីសណ្ដាយ

## ជាប្រភេទត្រីដែល
## កំពុងឈានទៅផុតពូជ



វានឹងញាស់នៅក្នុងរយៈពេលបីថ្ងៃក្រោយ។ នៅពេលកម្រិតទឹកជំនន់ទន្លេមេគង្គស្រកចុះ ត្រីសណ្ដាយក៏វិលត្រឡប់ចូលមេគង្គ ឬដៃទន្លេធំៗវិញ ជាទីដែលវាស្នាក់នៅក្នុងអាងទឹកជ្រៅទាំងនោះ រហូតដល់រដូវទឹកជំនន់លើកក្រោយចូលមកដល់។ ត្រីសណ្ដាយ ត្រូវបានគេកត់ត្រាចូលក្នុងបញ្ជីក្រហម IUCN Red List (Near Threatened) ជាប្រភេទត្រីកំពុងឈានទៅរងការគំរាមកំហែងរងគ្រោះផុតពូជក្នុងឆ្នាំ ២០១០។ ការនេសាទហួសកម្រិតពីអតីតកាល និងទៅអនាគត ជាបញ្ហាប្រឈមដ៏ធំមួយ ដែលជាមូលហេតុនៃការធ្លាក់ចុះចំនួនត្រីប្រភេទនេះ។ ចំណែកឯបញ្ហាប្រឈមដ៏មានសក្តានុពលផ្សេងទៀតគឺ កំណើតមនុស្សដែលចេះតែកើនឡើង និងបានបំផ្លិចបំផ្លាញទីជម្រករបស់វា ព្រមទាំងមានការប្រកួតប្រជែងពីប្រភេទត្រីចំណាកស្រុកមកពីខាងក្រៅតំបន់ផងដែរ។




ត្រីកញ្ជ្រូក មានឈ្មោះវិទ្យាសាស្ត្រ (*Yasuhikotakia modesta*) និងឈ្មោះជាភាសាអង់គ្លេស Redtail botia ជាប្រភេទត្រីទឹកសាប ដែលជាទូទៅមានរស់នៅតាមទន្លេធំៗ ដែលមានភក់នៅស្រទាប់ខាងក្រោម និងម្តងម្កាល វាចូលទៅក្នុងតំបន់វាលលិចទឹកផងដែរ។ ត្រីកញ្ជ្រូក មានប្រវែងដងខ្លួនអតិបរមា ២៥ ស.ម វារកចំណីស៊ីនៅពេលយប់ ដូចជាជន្លេន សិប្បីជាតិ និងសត្វល្អិតជាអាហារ។ ត្រីប្រភេទនេះ វាធ្វើចរាចរផ្លាស់ទីជាហ្វូង។ នៅផ្នែកខាងលើល្បាក់ខោន នៃអាងទន្លេមេគង្គ ត្រីកញ្ជ្រូកធ្វើចរាចរផ្លាស់ទីចូលទៅតាមដៃទន្លេ និងស្ទឹងតូចៗ ទីដែលវាអាចពង-កូន អំឡុងពេលមុនរដូវទឹកជំនន់ចូលមកដល់។ បន្ទាប់មក ពេលដែលទឹកចាប់ផ្តើមស្រក វាក៏ត្រឡប់ចូលមកតាមដៃទន្លេ និងទន្លេមេគង្គវិញ។ ការធ្វើចរាចរផ្លាស់ទីឆ្ពោះទៅខ្សែ

# ត្រីកញ្រ្ជូក

## ជាប្រភេទត្រីដែល
## មានការព្រួយបារម្ភតិចតួច



ទឹកខាងក្រោមល្បាក់ខោន ពីតំបន់ដីសណ្តទន្លេមេគង្គ ចាប់ពីខែវិច្ឆិកា ដល់ខែមិនា គឺកើតឡើងដោយសារទឹកទន្លេមេគង្គស្រកខ្លាំង ជាជំនួសមកវិញ ទឹកប្រៃក៏ហូរចូល។ ចាប់ពីខែឧសភា ដល់ខែកក្កដា ត្រីកញ្រ្ជូក ធ្វើចរាចរផ្លាស់ទីពីល្បាក់ខោន ចុះមកខ្សែទឹកខាងក្រោម ចូលទៅក្នុងតំបន់ទំនាបលិចទឹក ភាគខាងត្បូងប្រទេសកម្ពុជា និងតំបន់ដីសណ្តទន្លេមេគង្គ ក្នុងប្រទេសវៀតណាម។ ត្រីកញ្រ្ជូក ត្រូវបានគេកត់ត្រាចូលក្នុងបញ្ជីក្រហម IUCN Red List (Least Concern) ជាប្រភេទត្រីដែលមានការព្រួយបារម្ភតិចតួច ដែលអាចឈានទៅជាប្រភេទត្រីដែលរងគ្រោះជិតផុតពូជ ក្នុងឆ្នាំ ២០១១។ ត្រីប្រភេទនេះ ពុំមានព័ត៌មានច្បាស់លាស់អំពីបញ្ហាប្រឈមចំពោះពួកវានៅឡើយទេ។

USAID
FROM THE AMERICAN PEOPLE

University of Nevada, Reno

# អច្ឆរិយភាពនៃទន្លេមេគង្គ

# Wonders of the Mekong

A Foundation for Sustainable Development and Resilience

THE UNIVERSITY OF SYDNEY

FISHBIO

UtahState University

NSTA National Science Teachers Association